ធ្វើតេស្តខ្លួនឯង នៅផ្ទះ

របៀបប្រើ iHealth COVID-19 ធ្វើតេស្តខ្លួនឯង

1 → 2 → 3 → 4

ជំហានទី 1ៈ ត្រៀមសំភារៈរបស់អ្នក

អ្នកអាចមាន ប្រដាប់តេស្ត 1 ឬ ប្រដាប់តេស្ត 2 នៅក្នុងកញ្ចប់។ សូមធ្វើតាមជំហានត្រឹមត្រូវ យោងលើប្រដាប់ដាក់លាក់អ្នកបានទទួល។

ប្រដាប់តេស្ត 1 នឹងមកដោយមាន៖

បណ្ណតេស្ត COVID-19 | **បំពង់មួយ** ពេញដោយទឹកធ្វើតេស្ត | **សំឡីផ្ទិត**

នៅពេលអ្នកចាប់ ដើម្បីធ្វើតេស្ត បើកកញ្ចប់ក្រដាសស្អិតៗ នៃបណ្ណតេស្ត COVID-19
សូមទៅធ្វើនៅត្រង់ ជំហានទី **2** យកសំណាករបស់អ្នក

ប្រដាប់តេស្ត 2 នឹងមកដោយមាន៖





រកគែមពីរ នៅលើបំពង់ទទេ បន្ទាប់មកច្របាច់ល្បាយរាវដែលបានបិទជិត ចូលទៅក្នុងបំពង់ទទេ ធ្វើឲ្យប្រាកដ ថាកម្រិតទឹក គឺនៅលើគែមទី 2*
នៅពេលអ្នកចាប់ ដើម្បីធ្វើតេស្ត បើកកញ្ចប់ក្រដាសស្អិតៗ នៃបណ្ណតេស្ត COVID-19
សូមទៅធ្វើនៅត្រង់ ជំហានទី **2** យកសំណាករបស់អ្នក

**វាអាចទទួលយកបាន បើទឹកគឺនៅលើគែមទី 2 តែយ៉ាងណាមិញ សូមកុំបន្តធ្វើតេស្តនេះ បើសិនកម្រិតទឹក គឺក្រោមគែមទី 2 ព្រោះយ៉ាងនេះ អាចនឹងបណ្តាលឲ្យមានលទ្ធផលខុស ឬប្រឹការមិនបាន។*

ជំហានទី 2ៈ យកសំណាករបស់អ្នក



យកសំឡីផ្ទិត ចេញពីកញ្ចប់របស់វា
ចូរកុំប៉ះចុងសំឡីផ្ទិត ជាមួយម្រាមដៃរបស់អ្នក
ទុកកញ្ចប់សំឡីផ្ទិត សំរាប់ប្រើនៅពេលក្រោយទៀត

សិកចុងសំឡីផ្ទិតទាំងអស់ ដោយថ្នមៗ (តាមធម្មតា ½ ទៅ ¾ អ៊ិញ) ចូលក្នុងរន្ធច្រមុះរបស់អ្នក

ជាមួយនឹងក្មេងៗ អ្នកអាចសិកសំឡីផ្ទិត ឲ្យបានធ្លាយបំផុត ចូលក្នុងរន្ធច្រមុះ អាចនឹងតិចជាង ¾ អ៊ិញ ហើយអ្នកអាចនឹងត្រូវឲ្យមានមនុស្សម្នាក់ទៀត ដើម្បីទប់ក្បាលរបស់ក្មេង ក្នុងខណៈកំពុងផ្ទិត

ជុសសំឡីផ្ទិត ផ្នែកខាងក្នុងរន្ធច្រមុះរបស់អ្នក ជាអង្វង់មូល យ៉ាងហោច **5** ដង

ត្រូវឲ្យរឹងមាំ និងយឺតៗ - ចំណាយពេលយ៉ាងហោច **15** វិនាទី ដើម្បីយកសំណាក និងត្រូវឲ្យប្រាកដ ដើម្បីយកអ្វីៗដែលហូរ ក្នុងរន្ធច្រមុះ ដាក់លើសំឡីផ្ទិត

ការប្រើ **សំឡីផ្ទិតជជ្រៃ** ដោយធ្វើតាមរបៀបច្រំដែល សំរាប់រន្ធច្រមុះម្ខាងទៀត

អ្នកអាចនឹងបានលទ្ធផលមិនត្រឹមត្រូវឡើយ បើសិនអ្នកមិនយកសំណាក ឲ្យបានគ្រប់គ្រាន់ ជាមួយនឹងសំឡីផ្ទិតរបស់អ្នក

ជំហានទី 3ៈ ពិនិត្យសំណាករបស់អ្នក

គោះបំពង់ ដោយបញ្ឈរនៅលើតុ និងមូលគំរបធំពណ៌ក្រូច ដើម្បីបើក

ក្រូចចុងសំឡីផ្ទិត ឲ្យទៅដល់បាតនៃបំពង់ យ៉ាងហោច **15** ដង



ច្របាច់ចំហៀងនៃបំពង់ ដើម្បីយកសំណាកឲ្យបានច្រើនបំផុត ចេញពីសំឡីផ្ទិត
វាអាចនឹងមិនមានសំភារៈសំណាកគ្រប់គ្រាន់ ដើម្បីធ្វើតេស្តបានត្រឹមត្រូវទេ បើសិនអ្នកមិនច្របាច់សំឡីផ្ទិត

យកសំឡីផ្ទិតចេញ និងមូលក្អិត គំរបធំពណ៌ក្រូចវិញ នៅលើបំពង់

ដាក់សំឡីផ្ទិត ចូលក្នុងកញ្ចប់វិញ ដើម្បីបោះចោល

ជំហានទី 4ៈ ថែមសំណាក

សំណាករបស់អ្នក ឥឡូវនេះនៅក្នុងបំពង់ហើយ
បើកគំរបពណ៌សតូចនៃបំពង់ ដោយមូលវា ដើម្បីធ្វើតេស្តសំណាករបស់អ្នក
ថែមសំណាក 3 ដំណក់ ទៅក្នុងរន្ធបំពង់សំណាក នៃបណ្ណតេស្ត COVID-19
មូលក្អិត គំរបពណ៌សតូចវិញ
រង់ចាំ 15 នាទី សំរាប់លទ្ធផល របស់អ្នកបានស្រេចបាច់
ចាប់ផ្តើមរាប់នាទីភ្លាមៗ បន្ទាប់ពីថែមសំណាករបស់អ្នក ទៅក្នុងរន្ធបំពង់សំណាក។ លទ្ធផលនឹងស្រេចបាច់ ក្នុងពេល 15 នាទី ហើយនឹងផុតកំណត់ បន្ទាប់ពី 30 នាទី។
លទ្ធផលអវិជ្ជមានមិនពិត ឬលទ្ធផលវិជ្ជមានមិនពិត អាចនឹងកើតឡើង បើសិនលទ្ធផលតេស្ត ត្រូវបានអានមុន 15 នាទី ឬបន្ទាប់ពី 30 នាទី។

ការបកប្រែលទ្ធផល



លទ្ធផលវិជ្ជមាន

កត់សំគាល់ថា បន្ទាត់អក្សរ T អាចនឹងភ្លឺច្រាងៗ។ លទ្ធផលវិជ្ជមាន ត្រូវតែបង្ហាញនៅលើបន្ទាត់ C និងបន្ទាត់ T ទាំងពីរ។ លទ្ធផលវិជ្ជមាន មានន័យថា បុគ្គលម្នាក់គឺមានជំងឺ COVID-19។

ទៅមើល mass.gov/COVIDselftest ដើម្បីឲ្យដឹងត្រូវធ្វើខ្លះ។ អ្នកគួរតែទាក់ទង អ្នកផ្តល់ការថែទាំសុខភាពរបស់អ្នក អំពីលទ្ធផលវិជ្ជាមានរបស់អ្នក ជាពិសេស បើសិនអ្នកមានលក្ខណៈសុខភាពអ្វីមួយ ដែលធ្វើឲ្យអ្នកបិតក្នុងហានិភ័យ សំរាប់ជំងឺធ្ងន់ធ្ងរមកពី COVID-19។

លទ្ធផលអវិជ្ជមាន

លទ្ធផលអវិជ្ជមាន នឹងបង្ហាញតែបន្ទាត់ C។ លទ្ធផលអវិជ្ជមាន មានន័យថាបុគ្គលម្នាក់ បានសន្មត ថាគ្មានមានជំងឺ COVID-19។

លទ្ធផលអវិជ្ជមាន មិនសំរេចថាគ្មានជំងឺ COVID-19 ទាំងស្រុងទេ។ បើសិនអ្នកមានរោគសញ្ញានៃ COVID-19 ជាពិសេស បើសិនអ្នកដឹងថាអ្នក បានទៅកាន់អ្នកណាម្នាក់ ដែលមាន COVID-19 ត្រូវធ្វើតេស្ត នៅឯកន្លែងធ្វើតេស្ត ឬធ្វើតេស្តម្តងទៀត បន្ទាប់ពី 1-2 ថ្ងៃ និងប្រឹក្សាជាមួយអ្នកផ្តល់ការថែទាំសុខភាព របស់អ្នក។

លទ្ធផលមិនបានការ៖ បើសិនឥតមានបន្ទាត់ ឬបើសិនមានតែបន្ទាត់ T នោះការធ្វើតេស្ត គឺធ្វើមិនបានត្រឹមត្រូវទេ។ អ្នកនឹងត្រូវធ្វើតេស្តម្តងទៀត ជាមួយប្រដាប់ធ្វើតេស្តថ្មី។ បើសិនលទ្ធផលថ្មីរបស់អ្នក ក៏មិនបានការដែរ ត្រូវធ្វើតេស្តនៅកន្លែងធ្វើតេស្ត ឬទាក់ទងអ្នកផ្តល់ការថែទាំសុខភាព របស់អ្នក។

ចោលប្រដាប់ធ្វើតេស្ត បន្ទាប់ពីបានធ្វើតេស្តចប់ ចោលប្រដាប់អ្វីៗ ក្នុងធុងសំរាម។

សំរាប់ព័ត៌មានថែមទៀត ទៅមើល mass.gov/COVID19selftest